ការស្វែងយល់អំពីជីវិត

# លុយ

## ហេតុអ្វី នៅតែមិនគ្រប់?





# លុយ

## ហេតុអ្វី នៅតែមិនគ្រប់?

## "តែ១ដុល្លារទៀតប៉ុណ្ណោះ"

**លោកចន ដឺ រ៉ាកខាហ្វែលល័រ** (John D. Rockefeller) គឺជាមហាសេដ្ឋីអាមេរិក ដែលមានប្រាក់រាប់ពាន់លានដុល្លា ស្ថិតក្នុងចំណោមអ្នកមានទ្រព្យសម្បត្តិច្រើនបំផុត ក្នុងប្រវត្តិសាស្ត្រនៃសម័យទំនើប។ នៅពេលមួយ មានគេសួរគាត់ថា "តើមានលុយប៉ុន្មាន ទើបគ្រប់គ្រាន់?" គាត់ក៏បានឆ្លើយថា **"នៅខ្វះតែ១ដុល្លារទៀតប៉ុណ្ណោះ គឺគ្រប់គ្រាន់ហើយ"**។ ចម្លើយនេះ ត្រូវបានគេចុះផ្សាយ ក្នុងសារពត៌មានដ៏ល្បីល្បាញ។

ជាការពិតណាស់ តើមានមនុស្សប៉ុន្មាននាក់ ដែលចង់បានលុយបន្ថែម១ដុល្លាហើយ ១ដុល្លាទៀត មិនចេះស្កប់ស្កល់?" ស្តាប់ទៅមនុស្សយើងហាក់ដូចជាមិនដែលមានលុយគ្រប់គ្រាន់សោះ ទោះបីខ្លួនរកចំណូល ឬសន្សំបានច្រើនយ៉ាងណាក្តី។ យើងហាក់ដូចជាត្រូវបង់ថ្លៃនេះ បង់ថ្លៃនោះមិនចេះចប់ ហើយមានរបស់ជាច្រើនដែលចាំបាច់ត្រូវតែទិញ ឬត្រូវសន្សំលុយទិញ នៅថ្ងៃខាងមុខ។ ទោះយើងមានលុយល្មមនឹងបង់ថ្លៃអាហារ ការធ្វើដំណើរ និងទីជំរកហើយក្តី ក៏យើងនៅតែត្រូវត្រៀមលុយមួយចំណែក សម្រាប់ភាពចំបាច់នៅពេលអនាគត ដែលមានដូចជា ការអប់រំរបស់កូន ការសង្គ្រោះបន្ទាន់ផ្នែកសុខភាព និងការចូលនិវត្តន៍ជាដើម។

ហេតុនេះហើយ យើងក៏បានព្យាយាមរកប្រាក់ចំណូលបន្ថែម និងសន្សំឲ្យបានច្រើនថែមទៀត។ អ្នកខ្លះបានបន្ថែមម៉ោងធ្វើការ ដើម្បីឲ្យបានប្រាក់ឈ្នួលបន្ថែម។ ចំណែកឯអ្នករកស៊ីវិញ គេបានបើកទ្វារ

ហាងយូរជាងមុន។ អ្នកខ្លះទៀតក៏បានឆ្លៀតទៅធ្វើការងារក្រៅម៉ោងបន្ថែមទៀត។ គេបានព្យាយាមបង្កើនការវិនិយោគ ទៅលើផ្សារហ៊ុន ឬក៏កាត់បន្ថយចំណាយផ្សេងៗ ដើម្បីធ្វើឲ្យថវិការមានតុល្យភាព។

តើហេតុអ្វីបានជាមនុស្សយើងធ្វើនូវរឿងទាំងអស់នេះ? ពីព្រោះយើងមានតម្រូវការជាច្រើន ដែលត្រូវបំពេញ។ យើងចាំបាច់ត្រូវចិញ្ចឹមខ្លួនឯង និងក្រុមគ្រួសាររបស់យើង។ យើងត្រូវធ្វើយ៉ាងណា ឲ្យខ្លួនមានដំបូលជ្រក ហើយមានលទ្ធភាពមើលថែរឪពុកម្តាយយើង។ យើងត្រូវប្រាកដថា យើងមានលុយបម្រុងទុកខ្លះនៅក្នុងដៃ សម្រាប់ប្រើ ពេលនរណាម្នាក់ធ្លាក់ខ្លួនឈឺ ឬនៅពេលយើងបាត់បង់ការងារធ្វើជាដើម។ ដែលសំខាន់បំផុតនោះ មនុស្សយើងត្រូវការលុយដើម្បីរស់ ហើយក៏ត្រូវការសន្តិសុខខ្លះៗ នៅក្នុងផ្នែកហិរញ្ញវត្ថុផងដែរ។

យើងក៏មានចំណង់ផ្ទាល់ខ្លួន ដែលជាបំណងចិត្តពីកំណើត ដែលចង់អរសប្បាយនឹងផលកំរៃ នៃការប្រឹងប្រែងធ្វើការងារ។ មនុស្សទាំងអស់សុទ្ធតែចង់បានភាពស្កប់ចិត្ត និងសម្រេចបំណងរបស់ខ្លួន នៅក្នុងជីវិត មិនថាតែនៅថ្ងៃសម្រាកលំហែរជាលក្ខណៈគ្រួសារ ឬក្នុងឱកាសញ៉ាំអាហារថ្លៃៗយូរៗម្តង ឬក៏នៅក្នុងសកម្មភាពកម្សាន្តដែលយើងចូលចិត្តធ្វើ ក្នុងពេលទំនេរក្តី។

លើសពីនេះទៀត មនុស្សយើងមានសេចក្តីប្រាថ្នា។ អ្នកខ្លះបានស្វះស្វែងកសាងអនាគតឲ្យបានល្អជាងមុន សម្រាប់ខ្លួនឯង និងកូនៗរបស់ខ្លួន។ គេប្រហែលជាចង់បានឡានល្អជាមុន និងផ្ទះធំទ្រនំខ្ពស់ ឬក៏មានក្តីសុបិនចង់បង្កើតអាជីវកម្មផ្ទាល់ខ្លួនជាដើម។ គេក៏ព្យាយាមស្វែងរកសាលារៀនល្អៗឲ្យកូន ដើម្បីឲ្យពួកគេអាចមានការចាប់ផ្តើមដ៏ល្អ នៅក្នុងជីវិត ដើម្បីឲ្យពួកគេអាចមានអនាគតដ៏សប្បាយរីករាយ និងមានសុវត្ថិភាព។

តែគួរឲ្យស្តាយណាស់ តាមបទពិសោធន៍ដែលមនុស្សជាច្រើនបានឆ្លងកាត់ តម្រូវការ និងការចង់បានទាំងអស់នេះ អាចក្លាយជាបន្ទុក ដែលធ្វើឲ្យយើងមានភាពតានតឹងយ៉ាងខ្លាំង។ ការធ្វើការរាប់

ម៉ោង នៅកន្លែងធ្វើការ បានធ្វើឲ្យអ្នកខ្លះមានការហត់នឿយ ហើយគេមានការព្រួយបារម្ភ អំពីការបង់ថ្លៃនេះបង់ថ្លៃនោះមិនចេះចប់។ លុយសន្សំដែលចេះតែថយចុះ គឺជាការរំឭកថា ទោះយើងប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏នៅតែមិនគ្រប់គ្រាន់ដដែល។

ពេលខ្លះ បន្ទុកទាំងនេះអាចមានផលប៉ះពាល់ ដល់ផ្នែកផ្សេងៗទៀតនៃជីវិតយើង។ វាអាចប៉ះពាល់អាកប្បកិរិយា គុណតម្លៃ និងទំនាក់ទំនងជាមួយអ្នកដទៃ។ អ្នកខ្លះមិនអាចចំណាយពេលច្រើនជាមួយកូនៗ ដោយសារខំធ្វើការ ឬរកស៊ីខ្លាំងពេក ហើយក៏មានការឈ្លោះប្រកែកគ្នាក្នុងគ្រួសារ ដោយសារតែទម្លាប់នៃការចាយវាយហួសកំណត់។ អ្នកខ្លះទៀតប្រឹងប្រកួតប្រជែងនឹងមិត្តរួមការងារពេញទំហឹង ដើម្បីឲ្យបានរង្វាន់ និងឡើងតំណែង។ គេស្វែងរកការសម្រេចគោលបំណង ប៉ុន្តែគេបែរជាមានការព្រួយបារម្ភជាច្រើនវិញ។

គេស្វែងរកការសម្រេចគោលបំណង ប៉ុន្តែ គេបែរជាមានការព្រួយបារម្ភជាច្រើនវិញ។

តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាយើងនៅតែមានលុយមិនចេះគ្រប់? តើហេតុអ្វីបានជាយើង នៅតែ "ខ្វះលុយ ដោយចង់បាន១ដុល្លារហើយ ១ដុល្លាទៀតមិនចេះស្កប់ស្កល់?" តើយើងពិតជាចាំបាច់ត្រូវមានលុយបន្ថែមទៀត ដើម្បីបំពេញតម្រូវការរបស់យើងឬ?

## តើលុយធ្វើឱ្យពិភពលោកវិល ឬមួយយ៉ាងណា?

**ចូរយើងងាកមកមើលជីវិតពិត។** យើងឃើញថា លុយ*ពិតជា* អាចជួយដោះស្រាយបញ្ហាជាច្រើន ហើយយ៉ាងហោចណាស់ វាអាចទិញបានសុភមង្គលខ្លះៗដែរ។

យើងប្រើលុយទិញចំណីអាហារ ជម្រក និងចំណាយទៅលើមធ្យោបាយធ្វើដំណើរ និងឱសថព្យាបាលជម្ងឺជាដើម។ គេប្រើលុយសម្រាប់ចាយនៅថ្ងៃឈប់សម្រាក និងទិញរបស់ថ្លៃៗ ហើយវាអាចធ្វើឲ្យគេមានអារម្មណ៍ថា ខ្លួនមានសុវត្ថិភាព បើសិនជាគេបានសន្សំលុយខ្លះទុកប្រើ ពេលមានរឿងបន្ទាន់កើតឡើង ដូចជាជម្ងឺ ឬរឿងវិបត្តិអ្វីមួយ។ គេក៏ប្រើលុយបង់ថ្លៃសាលារបស់កូន ដោយសង្ឃឹមថា ពួកគេនឹងមានអនាគតល្អ។ ទោះជាយ៉ាងណាក៏ដោយ លុយមិនអាចធ្វើអ្វីៗគ្រប់យ៉ាងបានឡើយ។ មានតម្រូវការមួយចំនួនដែលលុយមិនអាចបំពេញឲ្យបាន ហើយលុយក៏មិនអាចសម្រេចក្ដីបំណងជាច្រើន។ វាពិតជាមិនអាចព្យាបាលចិត្តដែលមានរបួស ឬជួសជុលទំនាក់ទំនងដែលបែកប្រះស្រាំបានទេ។។ វាមិនអាចទិញមិត្តភាព ឬសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដបានដែរ។ វាមិនអាចជួយមនុស្សជាទីស្រឡាញ់ ឲ្យរស់ឡើងវិញ។ យើងអាចផ្ដល់ឲ្យកូនៗរបស់យើង នូវការអប់រំ និងរបស់លេងដ៏ល្អបំផុត ប៉ុន្តែ វានៅតែមិនអាចជួយឲ្យយើងមានភាពស្និទ្ធស្នាលជាមួយពួកគេ ព្រោះអ្វីដែលពួកគេត្រូវការបំផុត គឺពេលវេលារបស់យើងទៅវិញទេ។ យើងអាចរកបានរបស់ថ្លៃៗទាំងអស់ដែលយើងចង់បាន ប៉ុន្តែរបស់ទាំងនោះ នៅតែមិនអាចជួយឲ្យយើងឈប់មានអារម្មណ៍ឯកោ និងរកឃើញគោលបំណងនៃជីវិត។ លុយអាចនាំមកនូវភាពរំភើបរីករាយ និងសុភមង្គល ក្នុងរយៈពេលខ្លី ប៉ុន្តែ មិនអាចផ្ដល់ឲ្យយើង នូវក្ដីអំណរ និងការស្កប់ចិត្តរយៈពេលវែងឡើយ។

លោករ៉ាកខាហ្វេលល័រ( Rockefeller ) ដឹងច្បាស់ថា លុយពិតជាមិនអាចទិញសុភមង្គលបានមែន។ បុរសដែលមានលុយរាប់ពាន់លានដុល្លារម្នាក់នេះ ធ្លាប់និយាយថា "បើគេសន្និដ្ឋានថា មនុស្សមាន

ទ្រព្យសម្បត្តិច្រើនលើសលប់ តែងតែសប្បាយរីករាយជានិច្ច នោះមានន័យថា គេគិតខុសហើយ៉។

មានពេទ្យម្នាក់ដែលមានជំនាញបន្ថយការឈឺចាប់ នៅមន្ទីរពេទ្យក្នុងប្រទេសអូស្ត្រាលី មានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការថែទាំអ្នកជម្ងឺដែលជិតស្លាប់។ គាត់បានកត់ត្រា នៅក្នុងឯកសាររបស់គាត់ អំពីការ ស្តាយក្រោយខ្លាំងបំផុតទាំងប្រាំយ៉ាង ដែលអ្នកជម្ងឺនិយាយចេញមក នៅលើគ្រែ នៅពេលដែលពួកគេជិតផុតដង្ហើម។ ក្នុងចំណោមពួកគេ គ្មាននរណាម្នាក់និយាយថា ខ្លួនស្តាយក្រោយ ដែលមិនបានរកប្រាក់ចំណូលឲ្យបានកាន់តែច្រើននោះឡើយ។ តាមពិតក្នុងចំណោមវិបត្តិសារីដ៏ខ្លាំងបំផុតនោះ ពួកគេមានការស្តាយក្រោយយ៉ាងខ្លាំង ដែលពួកគេខិតខំធ្វើការងារខ្លាំងពេក។ មុនពេលផុតដង្ហើមមនុស្សភាគច្រើនសោកស្តាយ ដែលពួកគេមិនបានចំណាយពេលជាមួយមនុស្សជាទីស្រលាញ់ និងមិត្តភក្តិរបស់ពួកគេឲ្យបានច្រើន ឬមិនបានព្យាយាមរស់នៅ ឲ្យមានសុភមង្គលជាងនេះ។

តើមានពេលប៉ុន្មានដងហើយ ដែលអ្នកបានឮនរណាម្នាក់សុំពិនិត្យមើលទឹកប្រាក់ដែលខ្លួនមាន ក្នុងកុងធនាគារ មុនពេលខ្លួនជិតស្លាប់? អ្នកប្រហែលជាមិនធ្លាប់ឮគេស្នើរសុំបែបនេះទេ។ មនុស្សដែលជិតស្លាប់ ច្រើនតែមានបំណងប្រាថ្នាមួយ គឺចង់ឲ្យមនុស្សជាទីស្រលាញ់របស់គាត់ នៅក្បែរគ្រែគាត់ ដើម្បីឲ្យគាត់បានឱប ឬប៉ះកូន ឬចៅដែលគាត់ស្រឡាញ់ជាងគេ ឬដោះស្រាយជម្លោះជាមួយសាច់ញាតិណាម្នាក់ ជាលើកចុងក្រោយ។ នៅពេលដែលយើងឈានដល់ដំណាក់កាលចុងក្រោយនៃជីវិត អ្វីដែលយើងនៅមាននោះ គឺមិនមែនជាមាសប្រាក់ ឬរបស់ទ្រព្យនោះទេ តែយើងនៅសល់តែទំនាក់ទំនង និងអ្វីដែលកំពុងរង់ចាំយើងបន្ទាប់ពីយើងស្លាប់។

នៅទីបំផុត លុយគ្រាន់ជាក្របីសម្រាប់ជិះចម្លងភក់ប៉ុណ្ណោះ។ វាអាចជួយឲ្យយើងរកបានរបស់ជាច្រើន ប៉ុន្តែ មិនអាចផ្តល់ឲ្យយើងនូវអ្វីៗគ្រប់យ៉ាងនោះទេ។ វាមិនអាចបំពេញតម្រូវការ ចំណង់ និងមហិច្ឆិតា

ទាំងអស់ ដែលយើងមានឡើយ។

ដូច្នេះ តើយើងត្រូវធ្វើដូចម្ដេច? ប្រសិនបើលុយមិនមែនជាចម្លើយ សម្រាប់បញ្ហាទាំងអស់ដែលយើងមាន តើយើងអាចបំពេញតាមតម្រូវការ និងចំណង់របស់យើង យ៉ាងដូចម្ដេចវិញ? ហើយតើធ្វើដូចម្ដេច ឲ្យយើង អាចចៀសវាងការដេញតាមលុយដ៏ងប់ងល់?

## ការមើលឃើញអ្វីដែលសំខាន់ជាងលុយ

**អ្នកខ្លះព្យាយាមស្កប់ចិត្ត**នឹងអ្វីដែលពួកគេមាន។ ពួកគេជឿថា បើពួកគេអាចរៀនរស់នៅក្នុងជីវិតបែបសាមញ្ញ ដោយពេញចិត្តនឹងអ្វីដែលពួកគេមាន ព្រមទាំងមានតម្រូវការ និងការចង់បានកាន់តែតិចជាងមុន នោះពួកគេអាចចៀសវាងការជាប់ខ្លួន នៅក្នុងរកលុយឲ្យបានច្រើនជាងមុន ដោយមិនចេះស្កប់ស្កល់ ។

វិធីសាស្ត្រនេះមានអត្ថប្រយោជន៍ ប៉ុន្តែ វាក៏មានដែនកំណត់របស់វាផងដែរ។ ទីមួយ វិធីសាស្ត្រនេះ អាចធ្វើឲ្យយើងមិនអើពើរចំពោះតម្រូវការ និងការទទួលខុសត្រូវពិតប្រាកដ ដែលអាចនាំឲ្យមានផលវិបាកធ្ងន់ធ្ងរ។ ឧទាហរណ៍ យើងមិនអាចព្រងើយកន្តើយ ចំពោះសេចក្ដីត្រូវការ នូវចំណីអាហារ ទីជំរក និងការអប់រំរបស់កូនៗយើងបានទេ។ ហើយបើយើងមិនប្រឹងប្រែងធ្វើការឲ្យបានគ្រប់គ្រាន់ទេ នោះយើងប្រហែលជាមិនអាចរស់នៅ ឲ្យមានសក្ដានុពលពេញលេញនោះឡើយ។ ទីពីរ យើងប្រហែលជាគ្រាន់តែបដិសេធចំណង់ និងមហិច្ឆិតា ដែលមនុស្សមានជាធម្មតាប៉ុណ្ណោះ។ មិនយូរមិនឆាប់ យើងនឹងមានការពិបាក មិនអាចព្រងើយកន្តើយចំពោះតម្រូវការ និងការចង់បានទាំងនោះទៀត ហើយយើងនឹងមានអារម្មណ៍ថា មិនស្កប់ចិត្ត និងមិនពេញលេញដូចមុនទៀត។ យើងមិនអាចរកបានការស្កប់ចិត្តពិតប្រាកដ ដោយគ្រាន់តែព្យាយាមគិតបែបវិជ្ជមាន ឬជឿលើកម្មវាសនានោះឡើយ។

ប៉ុន្តែ យើងមានចម្លើយមួយ សម្រាប់បញ្ហានេះ។ យើងមិនចាំបាច់ត្រូវពឹងផ្អែកលើទ្រព្យសម្បត្តិ ដើម្បីបំពេញតម្រូវការគ្រប់យ៉ាង

របស់យើង ឬព្យាយាមបដិសេធន៍វាទាំងស្រុងនោះឡើយ ផ្ទុយទៅវិញ សូមយើងងាកមករកអង្គបុគ្គលមួយ ដែលអាចផ្តល់ឲ្យយើងនូវសុវត្ថិភាព និងភាពស្កប់ចិត្តពិតប្រាកដ។

ចូរយើងគិតស្រមៃ អំពីក្មេងតូចម្នាក់ ដែលបានទទួលសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ពីឪពុកម្តាយរបស់គាត់ ដោយអ្នកទាំងពីរតែងតែមើលថែរគាត់ជានិច្ច។ ក្មេងម្នាក់នេះប្រហែលជាមិនមានអ្វីច្រើនទេ។ គាត់មិនមែនជាអ្នកមាន ហើយប្រហែលមិនមានអ្វីទាំងអស់ដែលគាត់ចង់បាននោះឡើយ។ ប៉ុន្តែ គាត់នៅតែអាចមានអារម្មណ៍សប្បាយរីករាយ និងស្កប់ចិត្ត ប្រសិនបើគាត់ដឹងច្បាស់ថាឪពុកម្តាយគាត់ឲ្យតម្លៃចំពោះគាត់ ហើយនឹងមិនបោះបង់គាត់ចោល។

**យើងមិនអាចរកបានការស្កប់ចិត្តពិតប្រាកដ ដោយគ្រាន់តែព្យាយាមគិតបែបវិជ្ជមាន ឬជឿលើកម្មវាសនានោះឡើយ។**

ឥឡូវនេះ សូមយើងគិតស្រមៃដល់បុគ្គលម្នាក់ ដែលអាចផ្តល់ឲ្យយើង នូវសេចក្តីស្រឡាញ់ ដែលលើសសេចក្តីស្រឡាញ់ដែលឪពុកម្តាយអាចផ្តល់ឲ្យយើងទៅទៀត។ តើមាននរណាដែលអាចស្រឡាញ់យើង ដោយឥតលក្ខខណ្ឌ និងស្រឡាញ់ជារៀងរហូត ដោយមិនប្រែប្រួល ហើយគិតអំពីផលប្រយោជន៍របស់យើង?

មានតែព្រះដ៏ជាព្រះអាទិករទេ ដែលមានសេចក្តីស្រឡាញ់យ៉ាងនេះ ចំពោះយើង។

ព្រះអង្គជាព្រះដែលមានគ្រប់អំណាចចេស្តា ទ្រង់ជ្រាបអំពីអ្វីៗទាំងអស់ ហើយទ្រង់ជាព្រះដ៏អស់កល្ប ដែលស្គាល់ និងស្រឡាញ់យើងម្នាក់ៗ។ ដោយសារទ្រង់ជាអ្នកបង្កើតយើងម្នាក់ៗមក នោះទ្រង់ជ្រាបច្បាស់ថា យើងត្រូវការអ្វីខ្លះ។ ដោយសារតែទ្រង់ស្រឡាញ់យើង នោះទ្រង់ក៏គិតពីផលប្រយោជន៍របស់យើង ហើយប្រទានអ្វីៗដែលល្អ

សម្រាប់យើង។ ហើយដោយសារព្រះអង្គមានអំណាចចេស្ដា និងមានភាពអស់កល្ប នោះទ្រង់អាចធានាចំពោះយើងថា ទ្រង់គ្រប់គ្រងស្ថានភាព ជីវិត និងជោគវាសនារបស់យើង។

តើធ្វើដូចម្ដេច ឲ្យយើងអាចដឹងថា ព្រះអង្គពិតជាមានសេចក្ដីស្រឡាញ់យ៉ាងនេះ ចំពោះយើងមែន? យើងអាចដឹងបាន ព្រោះព្រះអង្គជាអ្នកមានបន្ទូលដោយផ្ទាល់។ គឺដូចដែលព្រះអង្គបានសន្យាថា ព្រះអង្គនឹងមិនចាកចេញពីយើង ក៏មិនបោះបង់ចោលយើងឡើយ (ហេព្រើរ ១៣: ៥)។

## ការទទួលយកទស្សនៈថ្មីមួយ សម្រាប់ជីវិត

**យើងបានកត់សម្គាល់ឃើញថា** លុយគ្រាន់តែជាមធ្យោបាយ ដែលយើងប្រើ ដើម្បីសម្រេចគោលបំណង ឬគោលដៅមួយចំនួន។ តែគួរឲ្យស្ដាយ មនុស្សយើងភាគច្រើនបានផ្ដោតអារម្មណ៍ ទៅលើមធ្យោបាយខ្លាំងពេក ជាជាងផ្ដោតអារម្មណ៍ទៅលើគោលដៅ។ យើងមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីការប្រមូលលុយឲ្យបានច្រើនថែមទៀត ជាហេតុធ្វើឲ្យយើងមិនសប្បាយចិត្ត។ ក្នុងការដេញតាមលុយមួយដុល្លាហើយមួយដុល្លាទៀតឥតឈប់ យើងក៏បានភ្លេចគិត អំពីការអ្វីដែលពិតជាសំខាន់ ក្នុងជីវិត។

ទោះជាយ៉ាងណាក៏ដោយ បើយើងងាកមករកព្រះវិញ ដូចជាកូនតូច ដែលសម្លឹងមើលទៅឪពុកម្ដាយដែលស្រឡាញ់ខ្លួន នោះទស្សនៈដែលយើងមានចំពោះជីវិត អាចចាប់ផ្ដើមផ្លាស់ប្ដូរ។ ដោយសារទ្រង់បានសន្យាថា យើងនឹងមានពេលអនាគតដ៏អស់កល្បជាមួយទ្រង់ នោះយើងអាចចាប់ផ្ដើមមើលរំលងតម្រូវការ និងការចង់បានក្នុងជីវិតនេះ ហើយមិនចាំបាច់ខ្វល់ខ្វាយ អំពីវាជាប្រចាំ ។ យើងអាចមានទំនុកចិត្ត និងការស្កប់ចិត្ត ពេលដែលយើងដឹងថា ព្រះជាម្ចាស់ស្រឡាញ់យើង គឺមិនខុសពីក្មេងដែលមានទំនុកចិត្ត និងការស្កប់ចិត្ត ពេលដែលវាដឹងថា ឪពុកម្ដាយវាស្រឡាញ់វានោះឡើយ។

ទស្សនៈដ៏ត្រឹមត្រូវនេះ បានជួយឲ្យសាវ័កប៉ុលអាចអត់ទ្រាំ ក្នុងជំនឿ សូម្បីតែនៅពេលដែលគាត់ជាប់ឃុំខ្លួន ក្នុងគុករបស់ចក្រភពរ៉ូម៉ាំង កាលពីជាង២០០០ឆ្នាំមុនក៏ដោយ។ គឺដូចដែលគាត់បានសរសេរក្នុងសំបុត្រ ទៅកាន់អ្នកជឿព្រះថា "ខ្ញុំធ្លាប់ទ្រាំឲ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមានទាំងខ្វះ ក្នុងសារពើទាំងអស់ហើយ ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ"(ភីលីព ៤: ១២-១៣)។

## ជំហានបន្ទាប់ តើយើងត្រូវធ្វើអ្វី?

ដូចនេះ តើយើងត្រូវទាញយកប្រយោជន៍អ្វីខ្លះពីលុយ? ប្រសិនបើយើងអាចមើលរំលងតម្រូវការ និងការចង់បានរបស់យើង ពេលដែលយើងជឿ និងងាកបែរមកព្រះជាម្ចាស់ តើយើងត្រូវមានអាកប្បកិរិយាយ៉ាងណាចំពោះលុយ?

ជាការពិតណាស់ ការងាកបែរទៅរកព្រះមិនមែនមានន័យថាយើងឈប់គិត អំពីតម្រូវការដែលយើងបានឃើញជាក់ស្តែងនោះឡើយ។ លុយពិតជាមានតួនាទីដ៏ពិតប្រាកដ និងមានប្រយោជន៍ ក្នុងការរស់នៅ សព្វថ្ងៃ ហើយវាក៏គ្មានអ្វីខុសដែរ ដែលយើងខំប្រឹងធ្វើការ និងខំប្រឹងសន្សំលុយ ប្រកបដោយប្រាជ្ញា។ បញ្ហាគឺយើងត្រូវទទួលស្គាល់ថា លុយមិនអាចធ្វើអ្វីៗគ្រប់យ៉ាងសម្រាប់យើងឡើយ។ បើសិនជាយើងពឹងផ្អែកលើលុយតែម្យ៉ាង ដើម្បីគ្រប់គ្រងការរស់នៅ និងជោគវាសនារបស់យើង នោះយើងងាយនឹងជាប់ផុងខ្លួន នៅក្នុងការស្វែងរកលុយមិនចេះស្កប់ស្កល់ ហើយជាលទ្ធផល យើងនៅតែមិនសប្បាយចិត្តដដែល។

បើយើងបោះយុថ្កាជីវិតរបស់យើង ឲ្យជាប់ក្នុងព្រះជាម្ចាស់ ជាជាងជាប់នៅក្នុងលុយ យើងនឹងមានទស្សនៈថ្មីចំពោះជីវិត និងចំពោះស្ថានភាពហិរញ្ញវត្ថុរបស់យើងផងដែរ។ យើងនឹងដឹងថា ព្រះកំពុងគ្រប់គ្រងជីវិតយើងទាំងស្រុង និងដឹងថា ទ្រង់ស្រឡាញ់ និងថែរក្សាយើង

ហើយដឹងទៀតថា ទ្រង់នឹងប្រទានឲ្យយើងមានកម្លាំងដើម្បីជម្នះឧបសគ្គក្នុងជីវិត។

តើលោកអ្នកចាំរឿងរបស់លោករ៉ាកខាហ្វែលល័រ (Rockefeller) ទេ? គាត់ជាមនុស្សដែលរកលុយបានច្រើនលើសលប់ នៅក្នុងជីវិត តែគាត់ដឹងថា គាត់អាចរកឃើញភាពស្កប់ចិត្ត នៅកន្លែងណា។ គឺដូចដែលគាត់មានប្រសាសន៍ថា "ក្នុងលោកនេះ គ្មានអ្វីដែលអាចប្រៀបផ្ទឹមនឹងការប្រកបគ្នារបស់គ្រីស្ទបរិស័ទឡើយ។ ក្រៅពីព្រះគ្រីស្ទ គ្មានអ្វីដែលអាចធ្វើឲ្យយើងស្កប់ចិត្តបានទេ"។

តើនេះគឺជាអ្វីដែលអ្នកកំពុងតែស្វែងរកឬ?

ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែមទៀត អំពីព្រះយេស៊ូវ អ្នកអាចទំនាក់ទំនងពួកជំនុំ ក្នុងតំបន់របស់អ្នក។ នៅទីនោះ នឹងមានមនុស្សដែលអាចជួយឆ្លើយសំណួរដែលអ្នកមាន។ យើងខ្ញុំនៅឯអង្គការនំម៉ាណាប្រចាំថ្ងៃ ក៏រង់ចាំស្វាគមន៍លោកអ្នកជានិច្ច។

ប្រសិនបើអ្នកចង់អានសៀវភៅផ្សេងទៀត ដែលទាក់ទងនឹងព្រះគម្ពីរ សូមចូលទៅកាន់វេបសាយរបស់យើងខ្ញុំ ដែលមានអាស័យដ្ឋាន www.khmer-odb.org/ds/។

ប្រែសម្រួលជាភាសាខ្មែរ ដោយ លោក លី ប៊ុនថា

ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ : លោក ឯក សត្យា

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2018 ODB Ministries (website: www.odb.org)

ចេញផ្សាយដោយ : ODB Cambodia (email: cambodia@odb.org, Tell: 087 233 907, website: http://khmer-odb.org, Facebook page : https://www.facebook.com/khmer.odb)